**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

## សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

**សភាព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៣២៦
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

**សាលដីកា**
លេខ ៥៤១ VII
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.ឯកឧត្តម [redacted] ចៅក្រម

៣.ឯកឧត្តម [redacted] ចៅក្រម

៤.ឯកឧត្តម [redacted] ចៅក្រម

៥.លោកជំទាវ [redacted] ចៅក្រម

**ចៅក្រមរបាយការណ៍**

-ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted]

**តំណាងមហាអយ្យការ**

-ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ២៤០ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បណ្តឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted]ញ្ញា សំណុំរឿងព្រហ្មទណ្ឌលេខ ៣២៦ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ របស់តុលាការកំពូលដែលមាន ៖

១.ជនជាប់ចោទឈ្មោះ [redacted]ស្រីណែត ហៅ ដា ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរអ្នកកាប់លុយ ទីកន្លែងកំណើតសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំ [redacted] សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ



Scanned with CamScanner

ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] "លែងលះ" មានកូនចំនួន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៣០៩ (ង) ដយដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ។

២.ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅ សិដ្ឋ ភេទប្រុស កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរលក់ឪស មានទីកន្លែងកំណើតនៅខេត្តព្រៃវែង អាសយដ្ឋានបច្ចុប្ប [redacted] សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] " នៅលីវ ជានីតិជន ។ (អ្នកប្តឹងសាទុក្ខ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៣០៨ (ង) ដយដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧។

-មានលោកស្រី [redacted] សុគន្ធ និងលោក [redacted] សុធន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

៣.ឈ្មោ [redacted] ញ្ញា ហៅ ឡា ឬ ប៊ិះ ភេទប្រុស កើតឆ្នាំ២០០០ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងសាក់ ទីកន្លែងកំណើតផ្សារលើ ក្រុងកំពង់សោម អ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោ [redacted] "ស" នៅលីវ ទោសពីមុនគ្មាន ជាអនីតិជន ។ (អ្នកប្តឹងសាទុក្ខ)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៣០៧ (ង)ដយដ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៧ ។

-មានលោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅត្រង់ចំណុចខុនដូរលេខ១២៥ (បន្ទប់លេខ៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ប្រហែលវេលាម៉ោងប្រមាណ១៦ និង១០នាទី ដោយមានការដឹកនាំសម្របសម្រួលពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កម្លាំងការិយាល័យប្រឆាំងជំនួញគ្រឿងញៀនខុសច្បាប់ នៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះអនុវត្តវិធានប្រគល់ដោយមានការឃ្លាំមើល ឬញុះញង់ឱ្យលក់គ្រឿងញៀនខុសច្បាប់ និងបានបង្ក្រាបចំពេលមុខសញ្ញាកំពុងធ្វើសកម្មភាព នៅចំណុចខុនដូរលេខ ១២៥ (បន្ទប់ ៥២) ផ្លូវលេខ ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដោយមានការឃាត់ខ្លួនជនសង្ស័យចំនួន ០១ នាក់ ឈ្មោះ [redacted] ស្រីណែត ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិខ្មែរ និងចាប់យកវត្ថុតាង សារធាតុញៀនប្រភេទមេតំហ្វេតាមីន (ICE) ទម្ងន់ ៣,៦៣ក្រាម ហើយភ្លាមៗនោះ យើងបាននាំខ្លួនជនសង្ស័យនេះទៅចង្អុលបង្ហាញបន្ទប់ខុនដូរលេខ៥២ របស់មេខ្លោង និងជាម្ចាស់សារធាតុញៀនប្រភេទមេតំហ្វេតាមីន (ICE) ទម្ងន់ ៤៩៥,៥០ ក្រាម ដោយឃាត់បានជនសង្ស័យចំនួន ២នាក់ មានឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ញ្ញា ភេទប្រុស អាយុ១៧ឆ្នាំ ហើយបានកសាងសំណុំរឿងបញ្ជូនជនសង្ស័យ និងវត្ថុតាងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។ (តាមលទ្ធផលកោសលវិច័យកម្រិតភាពសុទ្ធសរុប ៣៧៤,៣៥% នៃ



Scanned with CamScanner

ទម្ងន់សរុបជារបស់ឈ្មោះ [redacted] ពិសិដ្ឋ និងកម្រិតភាពសុទ្ធសរុប ២,៦៨% នៃទម្ងន់សរុបជារបស់ឈ្មោះ [redacted] ស្រីណែត ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ "វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោស

ក.ឈ្មោះ [redacted] ស្រីណែត ហៅ ដា ភេទស្រី អាយុ២៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន)រៀល ។

ខ.ឈ្មោះ [redacted] ពិសិដ្ឋ ហៅ សិដ្ឋ ភេទប្រុស អាយុ២៣ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលាន)រៀល ។

គ.ឈ្មោះ [redacted] បញ្ញា ហៅ ឡា ឬ បិះ ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ២០ (ម្ភៃ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (ហាសិបលាន)រៀល។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅត្រង់ចំណុចខុនដូរលេខ១២៥ (បន្ទប់លេខ៥២) ផ្លូវលេខ៤៤B សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

២.រឹបអូសវត្ថុចាប់យក តាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការ ត្រួតពិនិត្យគ្រឿងញៀន គឺ ៖

ក.ស្រោមសំបុត្រពណ៌គគីចំនួន១ សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀន ប្រភេទម្សៅក្រាមពណ៌សថ្លាទម្ងន់ ៤៩៥,៥០ក្រាម(បួនរយកៅសិបប្រាំក្បៀសហាសិបក្រាម)ដោយជនសង្ស័យឈ្មោះ [redacted] ពិសិដ្ឋ ផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង និង

ខ.ស្រោមសំបុត្រពណ៌គគីចំនួន ១ សរសេរថា កញ្ចប់វត្ថុតាងគ្រឿងញៀនប្រភេទម្សៅក្រាមពណ៌សថ្លាទម្ងន់ ៣,៦៣ ក្រាម (បីក្បៀសហុកសិបបីក្រាម) ដោយជនសង្ស័យឈ្មោះ [redacted] ស្រីណែត ផ្តិតមេដៃទទួលស្គាល់ និងហត្ថលេខាមន្ត្រីនគរបាលយុត្តិធម៌រួមជាមួយផង និង

គ.ទូរសព្ទដៃចំនួន ២ គ្រឿងមាន NOKIA ពណ៌ក្រហមលាយខ្មៅចំនួន ១ និងម៉ាក SAMSUNG ពណ៌សចំនួន ១ ចាស់ (មិនដំណើរការ) និងជញ្ជីងថ្លឹងចំនួន ២ ។

សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីណែត, ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៥០៩ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ "វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។



Scanned with CamScanner

-បានឃើញ បណ្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៥១៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ " វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ បណ្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៥៧២ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ "វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រV "វ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីណែត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]ិសិដ្ឋ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣.ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]បញ្ញា ហៅ ឡា ឬ ប៊ិះ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ "វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១, គ ដែលសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោ[redacted] បញ្ញា ហៅ ឡា ឬ ប៉ះ អាយុ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ២០ (ម្ភៃ) ឆ្នាំ ត្រូវកែប្រែមកជាដាក់ពន្ធនាគារកំណត់រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ វិញ។

ចំណុចផ្សេងពីនេះរក្សាទុកនៅដដែល។

៥.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីណែត, ឈ្មោ[redacted]ពិសិដ្ឋ និងឈ្មោះ [redacted] បញ្ញា និងប្រកាសជាអសាធារណៈ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ ។ ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២៤០ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងបណ្តឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted]បញ្ញា ប្តឹងមិនសុខចិត្ត នឹងសាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រV "វ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ ផន ពិសិដ្ឋ ។

-បានឃើញ សារណាការពារ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ សេង បញ្ញា ។



Scanned with CamScanner

-ចៅក្រមរបាយការណ៍បានឡើងធ្វើសេចក្ដីរាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋាននិងប្ដឹងសុំថា តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ឈ្មោះ [redacted] បញ្ញា ព្រមទាំងភស្តុតាងជាក់ស្ដែងនានា បញ្ជាក់ថា ជនជាប់ចោទទាំងពីរពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។ យល់ឃើញថា សាលាដំបូង និងសាលាឧទ្ធរណ៍ បានបន្ធូរបន្ថយទោសដល់ជនជាប់ចោទរួចហើយ ។ យល់ឃើញថា សាលដីកាព្រហ្មទណ្ឌរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ ។ ហេតុដូច្នេះ តំណាងមហាអយ្យការប្ដឹងសុំចំពោះតុលាការកំពូល តម្កល់សាលដីកាព្រហ្មទណ្ឌរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

-លោក [redacted] សុធន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅ សិដ្ឋ បានធ្វើសេចក្ដីសន្និដ្ឋានថា ចំពោះសេចក្ដីសម្រេចនៅតុលាការថ្នាក់ក្រោម គឺមិនបានពិចារណាទៅលើចម្លើយរបស់កូនក្ដីខ្លួននៅដំណាក់កាលអយ្យការ ក៏ដូចជាដំណាក់កាលចៅក្រមស៊ើបសួរ និងនៅពេលជំនុំជម្រះនោះទេ ។ ការឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ គឺកូនក្ដីខ្លួនបានឆ្លើយទាំងមានការគំរាមកំហែង ដោយឆ្លើយថាគ្រឿងញៀនដែលចាប់បានមានចំនួន ៤កញ្ចប់ ឯណោះ ។ ផ្ទុយទៅវិញ នៅដំណាក់កាលតុលាការថ្នាក់ក្រោមកូនក្ដីខ្លួនបានឆ្លើយសារភាពថា គ្រឿងញៀនដែលដកហូតបានជាក់ស្ដែងពីឈ្មោះ [redacted] ពិសិដ្ឋ នោះ គឺមានត្រឹមតែ ១កញ្ចប់ តែប៉ុណ្ណោះ ហើយចំពោះគ្រឿងញៀនដែលចាប់បានចំនួន ៤កញ្ចប់ នោះ គឺជារបស់ឈ្មោះ ៣រ ។ ដូច្នេះ កូនខ្លួនធ្វើការបដិសេធទៅគ្រឿងញៀនដែលមានចំនួន ៤៩៥,៨០g នេះ ចំណែកឯតុលាការថ្នាក់ក្រោមបែរជាមិនបានពិចារណាទៅលើគ្រឿងញៀន ១កញ្ចប់តូច ដែលបានដកហូតយកមកនោះទៅធ្វើការពិចារណានោះទេ ទាំងដែលកូនក្ដីខ្លួនបានឆ្លើយបដិសេធថា មិនមែនជារបស់ខ្លួន ។ ជាចុងក្រោយនេះ ស្នើសុំដល់ក្រុមប្រឹក្សាពិចារណាទៅលើអង្គហេតុ ដែលបានរៀបរាប់ខាងលើ និងគ្រឿងញៀនដែលបានដកហូតជាក់ស្ដែងចំនួន ១កញ្ចប់នេះ ។

-លោកស្រី [redacted] សុគន្ធ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅ សិដ្ឋ បានធ្វើសេចក្ដីសន្និដ្ឋានថា ខ្លួនឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់សហភាតា ។

-លោក [redacted] បូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា ឬ ប៊ិះ បានធ្វើសេចក្ដីសន្និដ្ឋានថា នៅពេលចាប់ខ្លួនកូនក្ដីខ្លួនមានអាយុត្រឹមតែ ១៧ឆ្នាំ តែប៉ុណ្ណោះ ដោយយោងតាមមាត្រា ១៦០ និងមាត្រា ១៦៤ បានបញ្ញត្តិពាក់ព័ន្ធទៅនឹងការទទួលប្រយោជន៍នៃស្ថានសម្រាលទោសចំពោះអនីតិជន ដូច្នេះយោងតាមមាត្រាខាងលើនេះ កូនក្ដីខ្លួនអាចធ្វើការផ្ដន្ទាទោសចន្លោះពី ១ឆ្នាំ រហូតដល់ ៥ឆ្នាំ ។ បន្ថែមពីនេះ មាត្រា ៥ នៃច្បាប់យុត្តិធម៌អនីតិជនឆ្នាំ២០១៦ ពាក់ព័ន្ធទៅនឹងការផ្ដន្ទាទោសទៅលើអនីតិជន ចំពោះការសម្រេចផ្ដន្ទាទោសត្រូវពិចារណាឱ្យបានទាបបំផុតតាមដែលអាចធ្វើទៅបាន ។ ស្របគ្នានេះដែរ មាត្រា ៣៧ ចំណុចទី២ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ក៏បានទាមទារឱ្យធ្វើការសម្រេចក្នុង



Scanned with CamScanner

ការផ្តន្ទាទោសទាបបំផុតតាមដែលអាចធ្វើទៅបានផងដែរ ។ សរុបសេចក្តីមក សាលាឧទ្ធរណ៍មិនបានពិចារណាទៅលើច្បាប់មួយចំនួន ដែលខ្លួនបានលើកឡើងមកនោះទេ អាស្រ័យហេតុនេះ ដើម្បីជាប្រយោជន៍ដល់កូនក្តីខ្លួនជាអនីតិជន ស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដើម្បីពិនិត្យទៅលើសំអាងហេតុផ្លូវច្បាប់ឡើងវិញ ។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅ សិដ្ឋ បានឆ្លើយថា ៖ គ្រឿងញៀនទាំង ៤កញ្ចប់ មិនមែនជារបស់ខ្លួននោះទេ ចំណែកគ្រឿងញៀនរបស់ខ្លួនមានត្រឹមតែ ១កញ្ចប់តូច តែប៉ុណ្ណោះ ។

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា ឬ ប៊ិះ បានឆ្លើយថា ៖ ខ្លួនឯកភាពតាមការធ្វើសេចក្តីសន្និដ្ឋានរបស់មេធាវីខ្លួន ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ
## តុលាការកំពូល

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤០ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅ សិដ្ឋ និងបណ្តឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា ឬ ប៊ិះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.យល់ឃើញថា៖ ការលើកឡើងរបស់លោក [redacted] សុធុន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ថា *"ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ដែលតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥១៤ ក្រ២ "វ" ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចផ្តន្ទាទោសកូនក្តីខ្លួនដាក់ពន្ធនាគារកំណត់ ២៣ឆ្នាំ ទុកជាបានការ គឺអយុត្តិធម៌ចំពោះកូនក្តីខ្លួន ដោយហេតុថា ចម្លើយនៅមុខនគរបាលយុត្តិធម៌ជាចម្លើយបានពីការបង្ខិតបង្ខំប៉ុណ្ណោះ ដាក់ស្តែងកូនក្តីខ្ញុំថា មានចំនួន១ កញ្ចប់តូចប៉ុណ្ណោះ ។ នៅសាលាឧទ្ធរណ៍ កូនក្តីខ្លួនបញ្ជាក់ម្តងទៀត កញ្ចប់ផ្សេងទៀតនៅក្នុងថង់ខ្មៅ គឺរបស់ឈ្មោះ [redacted] ឬពីវ ដែលឈ្មោះ ពីវ ឲ្យកូនក្តីខ្លួនទៅយក ។ ស្នើសុំពិចារណាលើគ្រឿងញៀន ១កញ្ចប់តូច ប៉ុណ្ណោះ។"* នោះ គឺមិនត្រឹមត្រូវទេ ពីព្រោះថា ជនជាប់ចោទបានឆ្លើយសារភាពហើយថា សមត្ថកិច្ចបានរកឃើញថ្នាំញៀនចំនួន ០១ កញ្ចប់ ជារបស់ខ្លួន ចំណែកថ្នាំញៀនចំនួន ៤ កញ្ចប់ទៀត ជារបស់ឈ្មោះ ពៅ ដែលបានផ្ញើខ្ញុំនៅមុននេះបន្តិច ហើយខ្លួនមិនដឹងថាជាថ្នាំញៀននោះទេ ។ ការបដិសេធថា មិនមែនជារបស់ខ្លួននោះ គឺ មិនមានភស្តុតាងដោះបន្ទុកឡើយ ។ ក្រៅពីនេះ តុលាការកំពូលយល់ស្របតាមសំអាងហេតុរបស់សាលាឧទ្ធរណ៍ភ្នំពេញ ។



Scanned with CamScanner

៣.យល់ឃើញថា ការលើកឡើងរបស់លោក [redacted]ប៉ូរ៉ា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា ឬ ប៊ិះ ថា *"កូនក្ដីរបស់ខ្លួនត្រូវបានចាប់ខ្លួនជាមួយឈ្មោ[redacted]ពិសិដ្ឋ ។ នៅពេលកូនក្ដីខ្ញុំមានអាយុ ១៧ឆ្នាំ ។ បណ្ដឹងសាទុក្ខទទួលបាន តាមមាត្រា៤១៧ ។ ច្បាប់គ្រឿងញៀន អនីតិជនត្រូវទទួលស្ថានសម្រាលដែរឬទេ? ត្រូវអនុវត្តមាត្រា ១៦០ និងមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ ដែលចន្លោះទោសពី ១ ដល់ ១៥ឆ្នាំ ។ បើប្រព្រឹត្តិដំបូង គឺត្រូវទទួលស្ថានសម្រាលក្រោម ១៥ឆ្នាំថែមទៀត តាមមាត្រា ៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន មាត្រា ៧ ចំណុច២ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ឆ្នាំ២០០៧ ពាក់ព័ន្ធនឹងការអនុវត្តច្បាប់អន្តរជាតិនៅកម្ពុជា គឺត្រូវបកស្រាយ ។ ដូច្នេះ ទាំងសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ភ្នំពេញ និង ការសម្រេចកូនក្ដីខ្លួនដែលជាអនីតិជន មិនទាន់ពិចារណាច្បាប់ឲ្យបានគ្រប់គ្រាន់នោះទេ។"* នោះ គឺមិនត្រឹមត្រូវទេ ពីព្រោះថា ជនជាប់ចោទឈ្មោះ[redacted] បញ្ញា ហៅ ឡា ឬ ជិះ ជាសហចារីបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រភេទមេតំហ្វេតាមីន មានទម្ងន់ ៤៩៥,៥០ក្រាម ដែលមានបរិមាណធាតុសុទ្ធទម្ងន់ ៤៩៥,៥០ក្រាម គុណ ៧៥,៥៥% ស្មើនឹង ៣៧៤,៣៤ក្រាម ដែលលើសពីបរិមាណដែលកំណត់តាមមាត្រា ៤០ កថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន *"អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ីមានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រាម ឡើងទៅ"* រហូតដល់ចំនួន ១៣៤,៣៤ក្រាម ឯណោះ ។ ចំណែកមូលទោសអនុវត្តចំពោះអនីតិជនចាប់ពីអាយុ ១៤ឆ្នាំ ឡើងទៅ តាមមាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ ទី២ និងទី៣ នៃក្រមព្រហ្មទណ្ឌ សម្រាប់មូលទោសដែលបានកំណត់តាមមាត្រា ៤០ កថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន *"អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ីមានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រាម ឡើងទៅ"* គឺរបៀបនៃការផ្ដន្ទាទោសត្រូវគិតដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ១៥ឆ្នាំ ឬ ២០ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ដូច្នេះ ដោយសារបរិមាណគ្រឿងញៀន "៣៧៤,៣៤ក្រាម" លើសពីកម្រិតអប្បរមាដែលកំណត់តាមច្បាប់ "២៤០ក្រាម" រហូតដល់បរិមាណ ១៣៤,៣៤ក្រាមបែបនេះ តុលាការកំពូលយល់ស្របនឹងការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ភ្នំពេញ ក្នុងការផ្ដន្ទាទោសលើជនជាប់ចោទឈ្មោ[redacted]បញ្ញា ហៅ ឡា ឬ ប៊ិះ ហើយការសម្រេចនេះ ស្របតាមចំណុចទី៥ មាត្រា៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន គឺបានកំណត់ជាគោលការណ៍មូលដ្ឋានថា **"...ការសម្រេចផ្ដន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន"** ។ ដោយឡែកមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ **"ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស"** មិនត្រូវអនុវត្តឡើយ ពីព្រោះថា ការទទួលស្ថានសម្រាល គឺត្រូវពិចារណាតាមមាត្រា ៩៣ ដល់មាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែមាត្រាទាំងនេះត្រូវបានហាមឃាត់ដោយមាត្រា ៣៣ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន រួចហើយ ។

៤.យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២៤០ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោ[redacted] ពិសិដ្ឋ ហៅ សិដ្ឋ និងបណ្ដឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជន



Scanned with CamScanner

ជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា ឬ បិះ មិនមានមូលហេតុត្រឹមត្រូវតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៥.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រV "រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមច្បាប់ហើយ ។

**ហេតុដូច្នេះ**

**សម្រេច**

១.**បដិសេធ** បណ្ដឹងសាទុក្ខលេខ ២៤០ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted]ពិសិដ្ឋ ហៅ សិដ្ឋ និងបណ្ដឹងសាទុក្ខលេខ ២៤១ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ហៅ ឡា ឬ បិះ ។

២. **តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ៦៦ ក្រV "រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ ។

| | | |
|---|---|---|
| -ឯកឧត្ដម | [redacted] | ប្រធាន |
| -ឯកឧត្ដម | [redacted] | ចៅក្រម |
| -ឯកឧត្ដម | [redacted] | ចៅក្រម |
| -ឯកឧត្ដម | [redacted] | ចៅក្រម |
| -លោកជំទាវ | [redacted] | ចៅក្រម |
| -លោក | [redacted] | ក្រឡាបញ្ជី |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃចន្ទ ៦ កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃចន្ទ ៦ កើត ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]



Scanned with CamScanner